# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**
លេខសំណុំរឿងព្រហ្មទណ្ឌ ៣៩៤
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ ៧៥៦
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣
សាលក្រមលេខ: **៨១(ខ)/១០០៤**
ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅនាទីសាលាដំបូងខេត្តសៀមរាប សាលសវនាការក១

កាលបរិច្ឆេទបើកសវនាការ ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ វេលាព្រឹក។

កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ វេលាព្រឹក។

### ក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សា |
| លោកស្រី | | ចៅក្រមប្រឹក្សា |
| លោកស្រី | | ចៅក្រមប្រឹក្សា |

### តំណាងអយ្យការ

| | | |
|---|---|---|
| លោកស្រី | [redacted] | ព្រះរាជអាជ្ញារង |

### ក្រឡាបញ្ជីសវនាការ

| | | |
|---|---|---|
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៤ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ និងសំណុំរឿងជំនុំជម្រះលេខ ៧៥៦ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted]សុខខ្សៀន ហៅ វ៉ា ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិគោកគ្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប មុខរបរ កសិករ ប្រពន្ធឈ្មោះ [redacted] លក្ខិណា មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ [redacted] លី (រ) ម្ដាយឈ្មោះ [redacted]លីម (រ) ទោសពីមុនគ្មាន ។ (ក្នុងឃុំ) **ដីកាបង្គាប់ឃុំខ្លួនលេខ: ២៦៤ យខ/ជ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣។**

ត្រូវបានជាប់ចោទពីបទ: **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអាយុរបស់ជនរងគ្រោះ** ប្រព្រឹត្តនៅភូមិគោកគ្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីឆ្នាំ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទ។

## គាគីដើមបណ្តឹងរដ្ឋប្បវេណី

- ឈ្មោះ [redacted] លក្ខិណា ភេទស្រី កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៨៦ ទីលំនៅបច្ចុប្បន្ននៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

- ជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា ភេទស្រី កើតថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៨ ទីលំនៅបច្ចុប្បន្ននៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

- ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធឲ្យជនរងគ្រោះ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៣ អយធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាដំណោះស្រាយលេខ ៤៤១២ ពស.ព្រទ/ជ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៧៧៣ ដកចត/២៣ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## អង្គហេតុកើតមានឡើងដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៨ នៅចំណុចភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឈ្មោះ [redacted] សុខឡែន ភេទប្រុស អាយុ៤២ឆ្នាំ (ត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះ) ខណៈពេលជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា បានទៅដេកនៅក្នុងបន្ទប់ប្អូនប្រុស ស្រាប់តែឈ្មោះ [redacted] សុខឡែន បានធ្វើសកម្មភាពចូលទៅក្នុងមុងរបស់ជនរងគ្រោះ ហើយចាប់បឺតមាត់ និងស្រាតខោ ព្រមទាំងយកប្រដាប់ភេទរបស់រូបគេដាក់ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ប៉ុន្តែដោយសារ ជនរងគ្រោះឈឺពេកក៏បានគេចចេញ ភ្លាមនោះឈ្មោះ [redacted] សុខឡែន បានចាប់ដៃជនរងគ្រោះជាប់ ហើយផ្តួលទៅលើគ្រែបន្ទាប់មកយកប្រដាប់ភេទរបស់រូបគេដាក់ចូលប្រដាប់ភេទរបស់ជនរងគ្រោះ បន្តរហូតចេញទឹកកាម ហើយនិយាយគំរាមជនរងគ្រោះថាកុំនិយាយប្រាប់ម៉ាក់ប្រយ័ត្នរូបគេ អាករចោល ថែមទៀត។ តាមចម្លើយរបស់ឈ្មោះ [redacted] សុខឡែន បានសារភាពថា កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ និងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ រូបគេពិតជាបានធ្វើសកម្មភាព ដូចខាងលើទៅលើកូនស្រីបង្កើតរបស់ខ្លួនឈ្មោះ [redacted] ម៉ុលនីកា ពិតប្រាកដមែន ។

## សិទ្ធិនិយាយស្តីរបស់គាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

- ជនជាប់ចោទឈ្មោះ [redacted] សុខឡែន បានធ្វើកំណត់សម្គាល់ថា: ស្នើសុំឲ្យតុលាការមេត្តាឲ្យខ្ញុំរួចផុតចោទប្រកាន់។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ ៖ តាងនាមជាតំណាងអយ្យការ ក្រោយពីបានធ្វើការដេញដោល ឃើញថាជនជាប់ចោទឈ្មោះ [redacted] សុខឡែន បានបញ្ជូនមកជម្រះពីបទៈ រំលោភសេពសន្ថវៈ

Scanned with CamScanner

មានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអាយុរបស់ជនរងគ្រោះ ប្រព្រឹត្តនៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីឆ្នាំ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។ នាពេលសវនាការជនជាប់ចោទបានឆ្លើយបដិសេធថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ តែមិនដឹងមូលហេតុអ្វីបានជាកូនស្រីបង្កើតឈ្មោះ [redacted] ម៉ុលីកា ប្តឹងខ្លួនទៅវិញ។ ចំពោះចម្លើយរបស់ជនរងគ្រោះឈ្មោះ ម៉ុលីកា បានឆ្លើយថាបានចោទប្រកាន់ឪពុករបស់ខ្លួន កើតឡើងដោយ សារខ្លួនមានការបារម្ភថា ឪពុកម្តាយរបស់ខ្លួន និងបំបែកខ្លួន ពីសង្សាររបស់ខ្លួន ដើម្បីទប់ទល់នឹងហេតុការណ៍នេះ ក៏សម្រេចប្តឹងឪពុកខ្លួនតែម្តង ហើយកន្លងមកពុករបស់ខ្លួនពុំដែលបានប្រព្រឹត្តនោះទេ គឺខ្លួនចេះតែប្រឌិតតែប៉ុណ្ណោះ។ ចំពោះម្តាយដែលជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លក្ខិណា ក៏បានឆ្លើយបដិសេធថាៈ ខ្លួនជឿជាក់លើប្តីខ្លួន១០០% តាំងពីការមកមិនដែលសង្ស័យថាប្តីខ្លួនបានរំលោភកូននោះទេ ចំពោះការប្តឹងប្តី ខ្លួននោះគឺជាការប្តឹងដោយមិនបានពិចារណាលើហេតុផល សរុបសេចក្តីមកទាំងគ្រួសារ ជនជាប់ចោទ , ដើមបណ្តឹង និងជនរងគ្រោះ រឿងដែលយើងលើកយកមកជំនុំជម្រះនេះជារឿងច្នៃប្រឌិត ប៉ុន្តែប្រសិនបើយើងបង្វែរ ការគិតទៅលើរឿងហេតុ កើតឡើងតាំងពីដំបូង ថាតើការអះអាងនោះដូចទៅនឹងអះអាងរបស់ជនរងគ្រោះដែរ ឬទេ ប្រសិនបើអំឡុងពេលនៃការកើតហេតុមានរយៈពេលត្រឹម៧ខែប៉ុណ្ណោះ។ នាពេលសវនាការយើងពិនិត្យឃើញថា ការឆ្លើយរបស់ជនរងគ្រោះពុំមានបញ្ហាអ្វីនោះទេ ដូច្នេះការឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ពុំឃើញមានភាពខុសប្រក្រតីនោះទេ។ ទី២ ពាក់ព័ន្ធនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាម្តាយ របស់ជនរងគ្រោះ បានចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ អង្គហេតុមិនបានដឹងទេ គឺដឹងពីប៉ូលីស មកវិញ កូនស្រីរបស់ខ្លួនត្រូវបានរំលោភបំពានពីប្តី ពេលនោះខ្លួនបានទៅសួរប្តី ហើយប្តីឆ្លើយថា យប់មិញស្រវឹង ដាក់មិនបានស៊ីជម្រៅអ្វីនោះទេ ហើយខ្លួនក៏សម្រេចដាក់ពាក្យបណ្តឹងទៅ។ ហើយពាក់ព័ន្ធជនជាប់ចោទចំពោះ អំណានចម្លើយគឺទទួលស្គាល់ទាំងអស់ មូលហេតុ និងភាពមិនប្រក្រតី នៃចម្លើយគឺគ្មាន យោងទៅលើ មន្ត្រី នគរបាលមិនអានចម្លើយមិនស៊ីសង្វាក់នោះទេ។ ផ្អែកទៅលើអះអាងរបស់ជនជាប់ចោទតែមួយមុខ គឺឆ្លើយ ដោះសារនាពេលសវនាការឃើញថាជាចម្លើយត្រឹមត្រូវ ឬ មិនត្រឹមត្រូវ គឺមិនអាចយកជាការទេ មានន័យថាជន ជាប់ចោទអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបានគ្រប់កាលៈទេសៈ គ្រប់ដំណាក់កាល តើគាត់បានប្រើប្រាស់ត្រឹមឬទេ? តំណាងអយ្យការយល់ឃើញថា ពាក់ព័ន្ធនឹងលទ្ធផលកោសល្យវិច្ច័យ តំណាងអយ្យការពុំសូវយកមកជាមូលដ្ឋាននោះទេ ផ្អែកលើរឿងនេះ ទាក់ទងនឹងអាយុជនរងគ្រោះ គាត់បានថា មុនពេលគាត់ទទួលរងការរំលោភបំពាន គឺគាត់ពុំដែលបានរួមភេទនោះទេ ពេលដែលទទួលពាក្យបណ្តឹងហើយបានធ្វើកោសល្យវិច្ច័យឃើញថាលទ្ធផលមានស្នាមដាច់ ហើយរយៈពេលជនជាប់ដែលឆ្លើយនៅមន្ត្រីនគរបាលយុត្តធម៌ក៏បានទទួលស្គាល់ដែរ។ តំណាងអយ្យការយល់ឃើញថា គឺមានអង្គហេតុបង្ខំឲ្យរួមភេទ ពិតប្រាកដមែន ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទជាឪពុករបស់ជនរងគ្រោះ ពិតប្រាកដមែន។ ប៉ុន្តែនៅពេលសវនាការជនជាប់ចោទបានឆ្លើយដោះសារ បដិសេធថាមិនបានប្រព្រឹត្ត យល់ឃើញថាមិនមែនជាមូលហេតុនៃការដោះបន្ទុកនោះទេ គឺជាការប្រើប្រាស់សិទ្ធិប៉ុណ្ណោះ យោងទៅលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ , ចម្លើយជនរងគ្រោះ និងលទ្ធផលកោសល្យវិច្ច័យវាមានភាពស៊ីសង្វាក់គ្នាទៅនឹងអំណានចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាជនជាប់ចោទឈ្មោះ [redacted] សុខឡែន ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ដូច្នេះតំណាងអយ្យការស្នើ

Scanned with CamScanner

សុំក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៣ អយធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ក្នុងកម្រិតអប្បបរមា។

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] សុខឡែន បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមក ឃើញ ថា ជនជាប់ចោទឈ្មោះ [redacted] សុខឡែន នៅតែរក្សាចម្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ទោះបីជាមានអង្គហេតុនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយសារភាព តែមន្ត្រីនគរបាលយុត្តិធម៌មិនបានអានចម្លើយឲ្យខ្លួនស្តាប់នោះទេ ខ្លួនក៏បានផ្តិតមេដៃ។ ដូច្នេះ បើយើងសិក្សាលើនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទ ត្រូវបានសន្មត់ថាគ្មានទោស ក្នុងករណីតុលាការមិនទាន់ប្រកាសទោសព្រហ្មទណ្ឌ ចូលជាស្ថាពរ។ ឃើញថា កំណត់ហេតុដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌គ្រាន់ជាព័ត៌មានមួយដែរកសាងឡើងដើម្បីឲ្យ តុលាការជឿក្នុងដំណាក់កាលចៅក្រមស៊ើបសួរជនជាប់ចោទក៏បានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ដោយឡែកពេលសវនាការចម្លើយរបស់ដើមបណ្តឹងក៏បានឆ្លើយបដិសេធ ហើយជនរងគ្រោះក៏បានឆ្លើយសារភាពថា ខ្លួនធ្វើការប្តឹងឪពុករបស់ខ្លួន ដោយសារខ្លាចបារម្ភថាឪពុករបស់ខ្លួននឹងប្តឹងសង្សារខ្លួន ហើយខ្លាចសង្សារមានទោសក៏បានប្តឹងទៅលើឪពុកវិញ។ នៅក្នុងដំណាក់កាលនេះ ស្នើសុំឲ្យតុលាការពិចារណាលើភស្តុតាងវិមតិសង្ស័យ ដោយជនជាប់ចោទ នឹងចម្លើយជនរងគ្រោះមានភាពមិនច្បាស់លាស់ ចំពោះអង្គហេតុមួយចំនួន ដោយសារជនជាប់ចោទពុំអានយល់ដឹងអំពីស្ថានភាពផ្សេងៗលើអង្គហេតុដែលបានលើកឡើង។ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ជនជាប់ចោទ និងភស្តុតាងដែលបានរកឃើញឡើង ជាពិសេស ចម្លើយនៅដំណាក់មន្ត្រីនគរបាល (ជាភស្តុតាងដែលមានវិមតិសង្ស័យ)។ ដូច្នេះខ្ញុំបានស្នើសុំឲ្យតុលាការពិចារណាអំពីភស្តុតាង និងពិចារណាសម្រេចឲ្យកូនក្តីខ្ញុំបាទរួចផុតបទចោទ។

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] សុខឡែន បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឯកភាព តាមលោក [redacted] ស៊ិនលាង។

## **ផ្អែកតាមកិច្ចពិភាក្សាដេញដោល**

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡែន
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីតា
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លក្ខិណា
- ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់ការកត់សម្គាល់របស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់

Scanned with CamScanner

# សំអាងហេតុ

- តាមរយៈដីកាដំណោះស្រាយលេខ ៤៤១២ ពស.ព្រទ/ជ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សុខឡែន ហៅ រ៉ា** ទៅជំនុំជម្រះពីបទៈ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអាយុរបស់ជនរងគ្រោះ** ប្រព្រឹត្តនៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីឆ្នាំ ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

- នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ រ៉ា បានឆ្លើយបដិសេធថា៖ ខ្ញុំបាទមិនទទួលស្គាល់អង្គហេតុ និងបទចោទប្រកាន់នោះទេ ដោយមូលហេតុខ្ញុំបាទមិនបានធ្វើសកម្មភាពរំលោភជនរងគ្រោះដែរជាកូនបង្កើតរបស់នាងខ្ញុំឈ្មោះ [redacted] ម៉ុលនីកា ឡើយ។ នៅពេលខ្ញុំបាទឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ សមត្ថកិច្ចមិនបានអានចម្លើយឲ្យខ្ញុំស្តាប់នោះទេ គឺឲ្យខ្ញុំផ្តិតមេដៃលើ កំណត់ហេតុចម្លើយតែម្តង។ នៅពេលដែលកូនស្រីបង្កើតបានប្តឹងខ្លួនពីបទៈ រំលោភសេពន្ថវៈ គឺខ្លួនមានអារម្មណ៍ថាឈឺចាប់។ នៅក្នុងពេលជាប់ពន្ធនាគារ ខ្ញុំមិនដែរមានអារម្មណ៍ខឹងនឹងកូនម្តងណាឡើយ ឲ្យតែកូនចូលមករស់នៅក្នុងផ្ទះវិញ ព្រោះសព្វថ្ងៃគេរស់នៅផ្ទះយាយ។ ខ្ញុំខឹងនឹងកូនខ្ញុំណាស់តែខ្ញុំមិនដែរជេរស្តីទេ ព្រោះដោយសារគ្រប់យ៉ាងហួសពេលអស់ទៅហើយ។ ខ្ញុំមិនបានប្រព្រឹត្តខុសនឹងកូនខ្ញុំទេ។ ម្យ៉ាងនៅដំណាក់កាលចៅក្រមស៊ើបសួរខ្ញុំក៏មិនបានឆ្លើយ សារភាពនឹងអង្គហេតុនោះទេ ចំពោះចម្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ខ្ញុំបាទសូមបដិសេធទាំងអស់ ព្រោះពេលនោះគេមិនបានអានចម្លើយឲ្យខ្ញុំបាទស្តាប់វិញនោះទេ មានតែសមត្ថកិច្ចស្រែកគម្រាម ខ្ញុំក៏ផ្តិតមេដៃទៅ។ ខ្ញុំនៅតែបដិសេធនៅចម្លើយដែលបានឆ្លើយនៅដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ ព្រោះខ្ញុំមិនបានប្រព្រឹត្តិនោះទេ។ កន្លងមកខ្ញុំធ្លាប់ហូបស្រាស្រវឹង ខ្ញុំក៏ធ្លាប់ឲ្យកូនស្រីកោសខ្យល់ អោយនៅក្នុងបន្ទប់ ហើយក្នុងបន្ទប់ក៏មានកូនអាយុប្រហែល៨ឆ្នាំដែរ។ ខ្ញុំមិនដែលនាំកូនទៅដើរលេងឯណា តែ០២នាក់នោះទេ។ ពេលកូនសុំទិញទូរស័ព្ទខ្ញុំក៏បានទិញអោយ តែមិនចាំតម្លៃទូរស័ព្ទនោះទេ។ ប៉ុន្តែផ្អែកតាមចម្លើយដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ បានបញ្ជាក់ថា ៖ នៅឆ្នាំ២០០៦ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] លក្ខិណា និងមានកូនជាមួយគ្នាចំនួន ០៣នាក់ ទី១ ឈ្មោះ [redacted] ម៉ុលនីកា ភេទស្រី អាយុ១៤ឆ្នាំ ទី២ ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ០៩ឆ្នាំ ទី៣ ឈ្មោះ [redacted] សុវណ្ណា ភេទប្រុស អាយុ០៤ឆ្នាំ។ លុះនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា ០៣រំលងអាធ្រាត ខ្លួនទៅដឹកដីនៅភូមិគោកដូង ស្រុកអង្គរជុំ រហូតដល់ថ្ងៃទី២៨ ខែឆ្នាំដដែលវេលាម៉ោង ២៤ និង០០នាទី ខ្លួនត្រឡប់មកផ្ទះវិញ ហើយបានដាស់ប្រពន្ធអោយបើកទ្វារ រួចងូតទឹកពេលនោះប្រពន្ធបានប្រាប់ឲ្យទៅដេកជាមួយកូនស្រីឈ្មោះ [redacted] ម៉ុលនីកា និងឈ្មោះ [redacted] សុវណ្ណារ៉ា ព្រោះមានកូនតូចខ្លាចខ្លួនដេកគង ពេលនោះខ្លួនបានដើរចូលទៅដេកនៅក្នុងបន្ទប់របស់កូនស្រី ពេលចូលទៅដល់កូនៗបានដេកលក់ ហើយខ្លួនបានចូលទៅដេកអោបកូនស្រីពីក្រោយ និងបានលាត់រ៉ូបកូនស្រីរួចយកដៃចាប់ប្រដាប់ភេទខ្លួនឯងលេងរហូតដល់ចេញទឹកកាម រួចក៏ដេកដល់ម៉ោង ០៣ និង០០នាទី ព្រឹក ទើបចេញមកវិញ។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ០៣ និង០០នាទី ខ្លួនបានចេញទៅដឹកដីនៅគោកដូង ស្រុកអង្គរជុំ លុះប្រហែលជាម៉ោង ២៤ និង០០ នាទី ខ្លួនបានត្រឡប់មកពីដឹកដីវិញហើយដាស់ប្រពន្ធអោយបើកទ្វារហើយបានងូតទឹក ពេលនោះ

Scanned with CamScanner

ប្រពន្ធបានប្រាប់ឲ្យទៅដេកក្នុងបន្ទប់ជាមួយកូនៗពេលចូលទៅដល់ក៏ឃើញរ៉ូបដែលកូនស្រីពាក់បានបើុងមកលើដោយឃើញដូចនោះខ្លួនក៏មានអារម្មណ៍ចង់រួមភេទហើយក៏ដាស់កូនស្រីឲ្យភ្ញាក់ខ្លួនក៏សុំរួមភេទជាមួយ ដោយធ្វើសកម្មភាពយកប្រដាប់ភេទរបស់ខ្លួនដាក់ចូលទៅក្នុងរន្ធគូទរបស់កូនស្រី បានចំនួន ២ ទៅ ៣ ដងក៏ចេញទឹកកាម រួចទៅដឹកដីនៅគោកដូង ដូចសព្វមួយដង។ លុះនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា ២០ និង០០នាទី ខ្លួនដេកជាមួយប្រពន្ធក្នុងបន្ទប់ លុះម៉ោង០១ប្រពន្ធបានដាស់ខ្លួនឲ្យទៅដេក ជាមួយកូនៗវិញខ្លួនក៏ចូលទៅដេក និងបានដាស់កូនស្រីសុំបញ្ចេញទឹកកាម កូនស្រីក៏ព្រមខ្លួនក៏ចាប់ផ្តើមស្រាតរ៉ូបកូនស្រី និងបានបឺតមាត់ លូកស្ទាបច្របាច់ដោះ និងស្ទាបលេងប្រដាប់ភេទកូនស្រីរហូតមានអារម្មណ៍ ខ្លួនក៏យកប្រដាប់ភេទរបស់ខ្លួនដាក់ចូលបានចំនួន០២ទៅ០៣ដង រហូតដល់ចេញទឹកកាម។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា ០២យប់ ខ្លួនក៏មានអារម្មណ៍ចង់រួមភេទជាមួយកូនស្រី ខ្លួនក៏លួចក្រោកទៅរកបើកទ្វារចូលទៅដាស់កូនប្រាប់ថា ឲ្យប៉ាសុំបញ្ចេញទឹកកាមម្តងទៀតមកហើយក៏ចាប់ដោះអាវ និងខោកូនស្រី ហើយអោបថើបបឺតមាត់ លូកស្ទាបច្របាច់ដោះ និងលូកលេងប្រដាប់ភេទកូនស្រីរហូតមានអារម្មណ៍ ទើបខ្លួនយកប្រដាប់ភេទដាក់ចូលក្នុងប្រដាប់ភេទរបស់កូនស្រីបានចំនួន២ទៅ៣ដងក៏ចេញទឹកកាមហើយបានគំរាមកូនថា បើហ៊ានប្រាប់រឿងយប់នេះឲ្យម៉ាក់ដឹងប៉ា និងអាករសម្លាប់ចោល រួចក៏ដើរចេញពីក្នុងបន្ទប់ទៅដេកជាមួយប្រពន្ធ។ លុះនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា ១២ ពេលខ្លួនមកពីដឹកដីក៏ឃើញកូន កំពុងតែលេងជាមួយប្អូនៗ នៅលើគ្រែក្នុងផ្ទះ ចំណែកប្រពន្ធកំពុងតែធ្វើម្ហូបនៅក្នុងរោងបាយ ពេលនោះខ្លួនក៏មានអារម្មណ៍ចង់រួមភេទក៏ដើរទៅសុំកូនស្រីឲ្យលេងប្រដាប់ភេទខ្លួនពេលនោះកូនក៏យល់ព្រមរួចខ្លួនបានដើរទៅលើគ្រែនៅខាងក្រៅផ្ទះ ហើយយកភួយគ្របខ្លួន បន្ទាប់មកកូនខ្លួនបានចូលក្នុងភួយហើយចាប់ប្រដាប់ភេទរបស់ខ្លួនលេងរហូតចេញទឹកកាមទើបក្រោកចេញទៅលេងជាមួយប្អូនៗនៅខាងក្រៅផ្ទះវិញ។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ពេលខ្លួនមកពីដឹកដីវិញហើយក៏ទៅងូតទឹករួចដេកជាមួយប្រពន្ធ រហូតដល់ម៉ោងប្រហែលជា ០១យប់ ខ្លួនមានអារម្មណ៍ចង់រួមភេទក៏ក្រោកដើរទៅបន្ទប់កូនស្រី ហើយដាស់ឲ្យភ្ញាក់ និងបានសុំរួមភេទ ពេលនោះកូនក៏យល់ព្រមខ្លួនក៏បានស្រាតខោអាវ និងស្រាតខោអាវកូនស្រី រួចបានលូកស្ទាប ច្របាច់ដោះ បៀម បឺត មាត់ និងយកមាត់បឺតប្រដាប់ភេទរហូតមាន អារម្មណ៍ បន្ទាប់មកយកស្រោមអនាម័យមកពាក់ប្រដាប់ភេទរបស់ខ្លួនរួចរុញចូលប្រដាប់ភេទកូនស្រីបានបន្តិចកូនស្រីបានប្រាប់ថា ឈឺហើយខ្លួនក៏ដកប្រដាប់ភេទចេញវិញបន្ទាប់មកក៏ដើរមកដេកជាមួយប្រពន្ធវិញ។

- តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡែន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: កាលពីឆ្នាំ២០១៨ ខ្លួនបានទៅរស់នៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ផ្ទះរបស់ខ្លួនមានចំនួន ០២បន្ទប់ មួយបន្ទប់សម្រាប់ខ្លួននឹងប្រពន្ធ ហើយមួយបន្ទប់ទៀត សម្រាប់កូន ០២នាក់ ដោយកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ម៉ុលនីកា គេងជាមួយប្អូនប្រុសឈ្មោះ [redacted] សុវណ្ណារ៉ា។ កន្លងមកខ្លួនធ្លាប់ចូលទៅគេងលេងជាមួយកូនទាំងពីរនាក់ជាធម្មតា។ ខ្លួនពុំបានស្ទាបអង្អែល លេងប្រដាប់ភេទ កូនស្រីខ្លួនទេ។ ខ្លួនមិនបានដឹងមូលហេតុអីទេ ហើយក៏មិនបានប្រព្រឹត្តស្ទាបអង្អែលដូចការចោទរបស់កូនស្រីខ្លួននោះទេ។ កន្លងមកខ្លួនធ្លាប់ថើបថ្ពាសកូនលេងមែនដោយពេលនោះកូនស្រីទើបតែមានអាយុ០៩ឆ្នាំទេ ក្រោយពីថើបរួចខ្លួនមិនបានធ្វើអ្វីទៀតនោះដែរ។ ខ្លួនមិនបានធ្វើសកម្មភាពស្ទាបអង្អែល ឬ ចាប់រំលោភកូនស្រីខ្លួនទេ ហើយខ្លួនធ្លាប់បានវាយកូនដោយ

Scanned with CamScanner

យកខ្សែមកវាយ ព្រោះកូនដើរលេងមិនចូលរៀន។ ចំណែកប្រពន្ធខ្លួនមានទំនាស់ ជាមួយគ្នាតិចតួចតែប៉ុណ្ណោះ។ ពេលប្រពន្ធទើបសម្រាលកូនរួចសសៃខ្ចី អំឡុងពេលនោះប្រពន្ធរបស់ខ្លួនបានឲ្យខ្លួនទៅគេងនៅបន្ទប់ជាមួយកូនស្រី ពេលនោះខ្លួនមិនបានធ្វើសកម្មភាពរំលោភកូន ដូចការចោទប្រកាន់ទេ។ ខ្លួនមិនទទួលស្គាល់ចម្លើលកាលដែលខ្លួនបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ទេ ព្រោះពេលនោះខ្លួនមិនបានឆ្លើយថាបានរំលោភកូនស្រីទេ។

- នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លក្ខិណា បានឆ្លើយបដិសេធថា ៖ នាងខ្ញុំជាប្រពន្ធរបស់ជនជាប់ចោទ ក្នុងគ្រួសារមានកូនចំនួន០៣នាក់។ ចំពោះអង្គហេតុ នោះមិនពិតប្រាកដមែននោះទេ ព្រោះការរួមរស់ជាមួយគ្នាជាប្តី ប្រពន្ធ មានការស្មោះត្រង់ និងដែលមានការ ផិតក្បត់នោះទេ ចំពោះការរស់នៅជុំគ្នា (រួមភេទ) ជាមួយប្តី ក៏គាត់ពុំមែនជាមនុស្សល្មោភកាមនោះដែរ។ ខ្ញុំបានរៀបការជាមួយប្តីបានរយៈ១៦ឆ្នាំហើយ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នា ពេលដែរខ្ញុំកំពុងមានរដូវ ក៏គាត់ពុំ ដែលបានបង្ខំខ្ញុំឲ្យរួមភេទនោះដែរ។ ចំពោះដើមហេតុនៃការប្តឹងនេះ គឺព្រោះខ្ញុំមិនដឹងថាកូនមានសង្សារ នោះទេ ពេលនោះខ្ញុំ និងប្តីបានទៅពឹងប៉ូលីសថា បាត់កូនស្រាប់តែគេកោះហៅទៅថា ប្តីខ្ញុំរំលោភកូនទៅវិញ។ ពីដំបូង កូនខ្ញុំបានបាត់ខ្លួនកាលពីថ្ងៃទី០១ ខែមីនា ហើយខ្ញុំបានតាមរក ដោយបានបាត់ខ្លួន០២ដង។ លើកទី០១ បាន បាត់ខ្លួន០១យប់ រំលងបាន១៥ ទៅ ១៦ថ្ងៃ ក៏បានបាត់ខ្លួនយូរ ក៏បានទៅដាក់ពាក្យបណ្តឹងរកកូនស្រី ពេលរកឃើញកូនស្រីវិញ ក៏បានដឹងដំណឹងថា ប្តីខ្លួន រំលោភកូនទៅវិញ។ ខ្ញុំមិនបានដឹងថាកូនមានសង្សារតាំងពីពេល ណានោះទេ តែមិនដឹងថាបានទាក់ទងជាមួយកូន អ្នកជិតខាងពីពេលណានោះទេ។ ពេលរកឃើញកូនស្រី កូនស្រី បានប្រាប់ខ្លួនថា "ប៉ាបានបៀតបៀនខ្លួនតាំងពីឆ្នាំ ២០២១" ហើយដោយសារពេលនោះខ្ញុំជឿកូនស្រីក៏បាន ប្រាប់ សមត្ថកិច្ចថា"ប្តីខ្ញុំបានបៀតបៀនកូន" តែតាមពិតគឺ កូនស្រីខ្លាចខ្ញុំប្តឹងសង្សារវា ក៏បានប្រាប់ខ្ញុំបែបនោះទៅ។ អំឡុងពេលដែររស់នៅផឹកស៊ី ចូលខារ៉ាអូខេ មាន។ មូលហេតុដែលខ្ញុំស្នើសុំឲ្យ ប្តីរួចផុតពីបទចោទ ព្រោះប្តីខ្ញុំមិនបានប្រព្រឹត្តបទៈរំលោភនោះទេ។ ហើយចម្លើយខ្ញុំគ្រប់ដំណាក់កាលគឺដូចគ្នា ពុំមានការផ្លាស់ប្តូរចម្លើយនោះទេ។ ពេលរស់នៅជាមួយគ្នា ប្តីខ្ញុំទៅធ្វើការរាល់ថ្ងៃ ហើយយូរៗមានការជួបជុំគ្នាម្តង ផឹកស៊ីចូលខារ៉ាអូខេ។ ខ្ញុំដឹងថារឿងនេះភាន់ច្រលំដោយសារកូនស្រីប្រាប់ ពេលនៅខ្លួនខឹងពេកក៏បានប្រាប់ប៉ូលីស តាមកូនស្រីប្រាប់។ ចំពោះចម្លើយដែរបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នៅពេលដែលកូនស្រីប្រាប់ ខ្ញុំក៏បានហៅប្តីមកសួរ ពេលនោះប្តីខ្ញុំឆ្លើយថា "មិនបានប្រព្រឹត្តិ" តែខ្ញុំមិនជឿ ប្តីខ្ញុំមិនដឹងធ្វើយ៉ាងម៉េចដោយសារ ខ្ញុំបានបង្ខំគាត់ពេក គាត់ក៏ព្រមស្បថ តាមខ្ញុំ។ នៅផ្ទះខ្ញុំមាន០២បន្ទប់ នៅពេលដែលខ្ញុំកូនខ្ចី គាត់នៅដេកជាមួយខ្ញុំដែរ ពេលកូនបានប្រហែល១ខែជាង ខ្ញុំក៏បានឲ្យប្តីទៅដេកជាមួយកូនស្រី និងកូនប្រុសតូច អាយុ០៨ឆ្នាំ។ នៅពេល នោះខ្ញុំក៏បានសួរកូនតូចដែរ ថាប៉ាមានធ្វើសកម្មភាពដាក់បងស្រីទេ ហើយកូប្រុសបានប្រាប់ថា "ប៉ាចូលទៅ ដេកក្នុងបន្ទប់ធម្មតា"។ ពីដំបូងខ្ញុំជឿកូនស្រី បន្ទាប់មកខ្ញុំជឿថាប្តីមិនបានប្រព្រឹត្តិនោះទេ (រឿងទាំងនោះ គឺជាការគិតរបស់ខ្ញុំតែប៉ុណ្ណោះ) ចាប់ពីកូនបានប្តឹងប្តី ខ្ញុំបានសួរកូនស្រីអពំពីរឿងនេះ ហើយកូនស្រីបានឆ្លើយថា "ដោយសារខ្លាចឪពុក និងម្តាយ ប្តឹងសង្សារខ្លួន ទើបខ្លួនសម្រេចថាពុកជាអ្នករំលោភខ្លួនទៅ"។

- ផ្អែកតាមស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លក្ខិណា ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាក់ថា: ខ្លួនបានរៀបការស្របច្បាប់ជាមួយឈ្មោះ [redacted] សុខឡៃន តាំងពីឆ្នាំ២០០៧ និងមានកូនចំនួន ០៣នាក់ ឯឈ្មោះ [redacted] ម៉ុលនីកា ភេទស្រី អាយុ១៤ឆ្នាំ

Scanned with CamScanner

ជាកូនទី១ ខ្លួនដឹងថាប្តីរបស់ខ្លួនជាអ្នកផឹកស៊ី ចូលហាង ចូលខារ៉ា អូខេ និងមានស្រីម្តង តែមិនជាប់លាប់ជាមួយស្រីក្រៅពីខ្លួនទេ។ តែនៅក្នុងឆ្នាំ២០១៩ ថ្ងៃមួយពេលព្រឹកកូនស្រីខ្លួនមានអាយុ១១ឆ្នាំ បានប្រាប់ខ្លួនថាកាលពីយប់មិញប៉ាចូលបន្ទប់ខ្លួន ទាំងស្រវឹងហើយលេងប្រដាប់ភេទរបស់ខ្លួន ហើយយកប្រដាប់ភេទរបស់គាត់ញល់ៗលើប្រដាប់ភេទរបស់ខ្លួនតែមិនបានដាក់ចូលនោះទេ ពេលលឺកូននិយាយដូចនោះ ខ្លួនបានហៅប្តីមក និងសួរតាមពាក្យសម្តីរបស់កូនពេលនោះប្តីខ្លួនឆ្លើយថា យប់មិញស្រវឹងពេកតែមិនបានស៊ីជម្រៅអ្វីទេ បន្ទាប់មកខ្លួនបានឲ្យប្តីឈប់ ធ្វើដូចនោះទៀត និងបានឲ្យប្តីខ្លួនស្បថទៀតផង តាំងពីពេលនោះ មកមិនដែលមានរឿងអ្វីទេ។ នៅក្នុងឆ្នាំ២០២២ ប្តីខ្លួនបានប្រើញញួរវាយទូរ និងសោរទ្វារបន្ទប់របស់កូន ដើម្បីគំរាមកូនកុំឲ្យដើរលេងផ្ទះគេរហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ កូនស្រីរបស់ខ្លួនបាត់ចេញពីផ្ទះ ដោយមិនដឹងមូលហេតុ ក្រោយមកខ្លួនបានមកប្តឹងនៅនគរបាលស្រុក ទើបនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ នគរបាលបាន រកឃើញកូនស្រីខ្លួន និងមនុស្សប្រុសម្នាក់ឈ្មោះ ដែន រហូតដល់សព្វថ្ងៃទើបខ្លួនដឹងរឿងពីនគរបាល វិញថា ប្តីរបស់ខ្លួនបានរួមភេទជាមួយកូនស្រីរបស់ខ្លួនចំនួនច្រើនដងៗ និងបានដឹងថាប្តីបានគំរាមថា សម្លាប់កូនបើសិនជាហ៊ានប្រាប់រឿងមកខ្លួន។ ខ្លួនសូមសំនូមពរសុំមិនប្តឹងផ្តល់អំពីប្តីរបស់ខ្លួននោះទេ។

- នាពេលសវនាការជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា បានឆ្លើយបដិសេធថា ៖ សព្វថ្ងៃខ្ញុំឈប់សិក្សាហើយ ខ្ញុំធ្លាប់បានរៀនដល់ថ្នាក់ទី១០។ មនោសញ្ចេតនាខ្ញុំជាមួយគ្រួសារមានទំហំ ៨០% និង ២០% បានបែងចែកទៅឲ្យសង្សារខ្ញុំ។ ចំពោះអង្គហេតុ និងបទចោទប្រកាន់ ចំពោះឪពុកខ្លួន គឺមិនពិតនោះទេ ដោយសារតែឪពុកមិនបានរំលោភ ខ្ញុំពិតប្រាកដមែន ដំបូងដោយសារខ្ញុំ ខឹងឪពុកម្តាយ បំបែកបំបាក់ខ្ញុំ នឹងសង្សារ។ កន្លងមកខ្ញុំធ្លាប់រួមភេទជាមួយសង្សារបានចំនួន០២ ទៅ០៣ដង អំឡុងពេលមានរឿង។ តាំងពីឆ្នាំ២០២០មក ខ្ញុំមិនដែលបានរួមភេទជាមួយសង្សារខ្ញុំនោះទេ ខ្ញុំទើបតែរួមភេទជាមួយសង្សារនៅពេលដែលម្តាយយកខ្ញុំទៅធ្វើផ្ទះយាយ គឺក្រោយពេលឪពុកជាប់ពន្ធនាគារ។ កន្លងមកឪពុកម្តាយមិនបានដឹងថាខ្លួនទាក់ទងជាមួនសង្សារនោះទេ ឪពុក ម្តាយបានដឹងថាមានសង្សារ នៅពេលដែលឪពុកខ្លួនមិនទាន់ជាប់ទោស។ ម្តាយប្តឹងសង្សារខ្ញុំមុនប្តឹងឪពុកហើយ ខ្ញុំក៏មិនបានដឹងថាប្តឹងពីបទអ្វីនោះទេ។ ក្រោយពីម្តាយបានប្តឹងសង្សារខ្ញុំបានកន្លះឆ្នាំ ទើបខ្ញុំក៏បានឲ្យម្តាយខ្ញុំប្តឹង ឪពុកខ្ញុំ ព្រោះខ្ញុំខឹងគាត់ប្តឹងសង្សារខ្ញុំ។ អំឡុងពេល០៦ខែនោះ ខ្ញុំនៅទាក់ទងជាមួយសង្សារខ្ញុំនៅឡើយ ហើយមានការចេញចូល ជួបគ្នាធម្មតា។ ពុកម្តាយមិនបានហាមឃាត់ទៀតនោះទេ តាំងពីពេលដែលគាត់យកខ្ញុំទៅធ្វើនៅផ្ទះយាយ។ នៅក្នុងគ្រួសារពុកខ្ញុំជាមនុស្សស្លូត មិនដែលប្រើប្រាស់ហិង្សាលើខ្ញុំទេ ហើយពេលស្រវឹងក៏មិន ដែលបានធ្វើអ្វីដល់ខ្ញុំនោះដែរ។ មូលហេតុដែលខ្ញុំឲ្យម្តាយទៅប្តឹងពុក ដោយសារពេលនោះខ្ញុំខឹងគាត់ប្តឹងសង្សារខ្ញុំ។ ហើយមកទល់ពេលនេះខ្ញុំមិនបានទទួលការបញ្ជោះឲ្យឆ្លើយនៅក្នុងសវនាការនោះដែរ។ ចំពោះចម្លើយដែរ បានឆ្លើយនៅដំណាក់កាលមុនៗ គឺខ្ញុំសុំបដិសេធចោល ដោយសារពេលនោះខ្ញុំខឹងចេះតែនិយាយៗទៅ។ មុនពេលធ្វើកោសល្យវិច្ឆ័យ ខ្ញុំមិនដែលបានរួមភេទជាមួយសង្សារនោះទេ។ មូលហេតុដែលខ្ញុំប្តឹងឪពុកខ្ញុំ ដោយសារតែគាត់មិនឲ្យខ្ញុំទាក់ទងនឹងសង្សារខ្ញុំ។ ខ្ញុំបានរួមភេទជាមួយសង្សារខ្ញុំនៅអំឡុងឆ្នាំ២០២៣។ ខ្ញុំមិនបានខឹងនឹងឪពុកនោះទេ ហើយឪពុកមិនមែនជាអ្នកធ្វើខុសដាក់ខ្ញុំទេ ខ្ញុំទេ ជាអ្នកធ្វើខុសដាក់ឪពុក។

- តាមការស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទីខែមិនចាំ ពេលដែលខ្លួនអាយុ

០៤ឆ្នាំ ឪពុកម្តាយរបស់ខ្លួនបានទៅយាមដីផ្ទះឲ្យគេនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពេលនោះឪពុករបស់ខ្លួនធ្លាប់បានយកដៃលូកស្ទាបលេងប្រដាប់ភេទរបស់ខ្លួនមួយលើក ហើយបន្ទាប់មកនៅពេលខ្លួនមានអាយុ០៦ឆ្នាំ ឪពុកម្តាយរបស់ខ្លួនបានទៅរស់នៅភូមិជ្រៃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដោយទិញដីធ្វើផ្ទះនៅទីនោះ។ កាលនោះឪពុករបស់ខ្លួនបានយកដៃលូកស្ទាបលេងប្រដាប់ភេទរបស់ខ្លួនមួយលើកដែរ។ លុះរស់នៅទីនោះបានប្រហែល០១ឆ្នាំក៏ប្តូរទីលំនៅមករស់នៅក្នុងភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប រស់នៅបានប្រហែល១ឆ្នាំ ដោយខ្លួនមានអាយុ០៩ឆ្នាំ ឪពុករបស់ខ្លួនបានលេងប្រដាប់ភេទរបស់ខ្លួនម្តងទៀត ដោយម្តាយរបស់ខ្លួនក៏ដេកនៅទីនោះដែរ តែម្តាយខ្លួនពុំបានដឹងថា ឪពុករបស់ខ្លួនធ្វើអ្វីលើខ្លួនទេ។ លុះ០១ខែក្រោយមកពេលយប់ខ្លួនបានដេកក្នុងបន្ទប់រួបជាមួយប្អូនប្រុស បានមួយសន្ទុះភ្ញាក់ឡើងក៏ឃើញឪពុករបស់ខ្លួននៅក្នុងបន្ទប់ដែរ ហើយបើកមុងចូលមករកខ្លួនហើយអោបថើប និងបឺតមាត់ខ្លួន បន្ទាប់មកក៏ស្រាតខោខ្លួនចេញហើយយកប្រដាប់ភេទរបស់គាត់ ដាក់បញ្ចូលក្នុងប្រដាប់ភេទរបស់ខ្លួន តែដោយឈឺពេកខ្លួនក៏គេចចេញពេលនោះឪពុកខ្លួនក៏បានចាប់ទាញខ្លួនមកវិញដោយចាប់ដៃដាប់ ហើយផ្តួលទៅលើគ្រែ បន្ទាប់មកគាត់ក៏ដាក់ប្រដាប់ភេទរបស់គាត់ចូលទៅក្នុងប្រដាប់ភេទរបស់ខ្លួនម្តងទៀត រហូតទាល់តែគាត់ចេញទឹកកាមដាក់លើប្រដាប់ភេទរបស់ខ្លួន ហើយបានគំរាមថា កុំនិយាយប្រាប់ម៉ាក់ប្រយ័ត្នខ្លួនអាករចោល។ ឪពុករបស់ខ្លួនតែងតែ ចាប់រំលោភខ្លួនរៀងរាល់០១សប្តាហ៍ ឬកន្លះខែម្តង រហូតមកដល់ឆ្នាំ២០២១ នៅថ្ងៃខែពុំចាំពេលនោះឪពុករបស់ខ្លួនបានផឹកស្រាស្រវឹងហើយសម្លឹងមកមើលខ្លួនដោយឃើញសភាពដូចនោះខ្លួនខ្លាច គាត់ចាប់រំលោភខ្លួនទៀត ក៏រត់ទៅដេកនៅ ផ្ទះអ៊ុំនៅភូមិកញ្ញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ លុះព្រឹកឡើងម្តាយរបស់ខ្លួនក៏ទូរស័ព្ទទៅរកខ្លួនហើយសួរខ្លួនថា នៅឯណាខ្លួនឆ្លើយ ថានៅផ្ទះអ៊ុំ ម្តាយខ្លួនសួរទៀតថានៅធ្វើអ្វីខ្លួនក៏ឆ្លើយថា ខ្លាចប៉ា ព្រោះប៉ាធ្លាប់ចាប់រំលោភខ្លួន ម្តាយក៏សួរថាយូរហើយនៅតាំងពីកាលណា ខ្លួនក៏ឆ្លើយថា យូរហើយតាំងពីរស់នៅភូមិចុងកៅស៊ូមកម្លេះ ពេលនោះម្តាយខ្លួនក៏ហៅខ្លួនឲ្យត្រឡប់មកផ្ទះវិញ ដោយឲ្យឪពុកខ្លួនស្បថ និងសន្យាថាឈប់ចាប់រំលោភខ្លួនទៀត។ ក្រោយពីធ្វើកិច្ចសន្យាហើយ ឪពុកខ្លួនក៏ឈប់ចាប់រំលោភខ្លួន ប៉ុន្តែនៅតែមានអាកប្បកិរិយាមួម៉ៅ និងប្រច័ណ្ឌនៅពេលដែលខ្លួនដើរលេងជាមួយមិត្តភក្តិប្រុស ដោយឃើញបែបនេះ ខ្លួនក៏រត់ទៅដេកនៅស្រែណ្ឌាយ ដែលជាផ្ទះរបស់សង្សាខ្លួន តែពុំបានរួមភេទជាមួយគ្នាទេ លុះព្រឹកឡើងក៏ត្រឡប់មកផ្ទះវិញ។ ខ្លួនបានបញ្ជាក់ថា រៀងរាល់ចាប់រំលោភរួចហើយ ឪពុកខ្លួនតែងតែគំរាមខ្លួនថា មិនឲ្យប្រាប់ម៉ាក់ទេបើហ៊ានប្រាប់នឹងសម្លាប់ខ្លួនចោល។

- ជនជាប់ចោទឈ្មោះ [redacted] **សុខឡែន ហៅ វ៉ា** បានឆ្លើយបដិសេធថា ខ្លួនមិនបានធ្វើសកម្មភាពចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា ទេ ដោយបានបញ្ជាក់ថាចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវបានគេអានចម្លើយឱ្យស្តាប់។ ប៉ុន្តែផ្អែកតាមចម្លើយរបស់ជនរងគ្រោះ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមស៊ើបសួរ បានបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] សុខឡែន ពិតជាបានរំលោភសេពសន្ថវៈ លើខ្លួនពិតប្រាកដមែន ម្យ៉ាងវិញទៀតជនរងគ្រោះបានឆ្លើយថា ខ្លួនមិនបានដែលរួមភេទពីមុនមកទេ ទើបតែរួមភេទក្រោយពេលជនជាប់ចោទ(ឪពុក) ជាប់ពន្ធនាគារតែប៉ុណ្ណោះ ប៉ុន្តែផ្អែកតាមកោលសវិច្ឆ័យឃើញថា សន្ទះព្រហ្មចារី របស់ជនរងគ្រោះ មានការដាច់រហែក និងមានស្លាកដាំខ្លាំង ដែលជាសញ្ញាបញ្ជាក់ថា ធ្លាប់បានរួមភេទពីមុនមក។ ចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខឡែន គ្រាន់តែជាចម្លើយដោះសារ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវតែ

Scanned with CamScanner

ប៉ុណ្ណោះ ហើយជនជាប់ចោទ មិនមានភស្តុតាងដោះបន្ទុកនោះទេថា ចម្លើយជនជាប់ចោទគ្រាន់តែឆ្លើយដើម្បីបិទបាំងនូវអំពើល្មើសរបស់ខ្លួនតែប៉ុណ្ណោះ ដែលមិនអាចឱ្យតុលាការជឿជាក់បានឡើយ។

- ដើមបណ្ដឹងរដ្ឋប្បវេណី [redacted] លក្ខិណា បានឆ្លើយបដិសេធ និងប្ដូរចម្លើយនៅសវនាការថា៖ ជនជាប់ចោទឈ្មោះ [redacted] សុខឡែន មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយសារពេលនោះខ្លួនជឿតាមសម្ដីកូន ហើយខឹងប្ដី និងបង្ខំប្ដីឲ្យសារភាព ឃើញថាចម្លើយរបស់ដើមបណ្ដឹងគ្រាន់តែឆ្លើយដោះសារដើម្បីឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតចម្លើយរបស់ដើមបណ្ដឹងពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីដោះបន្ទុកឱ្យជនជាប់ចោទ និងឱ្យតុលាការជឿជាក់បានឡើយ។

- ជនរងគ្រោះឈ្មោះ [redacted] ម៉ុលនីកា បានឆ្លើយបដិសេធ និងប្ដូរចម្លើយនៅសវនាការថា៖ ជនជាប់ចោទឈ្មោះ [redacted] សុខឡែន មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយសារពេលនោះ ខ្លួនខឹងនឹងឪពុកម្ដាយដែលប្ដឹងសង្សារខ្លួន ប៉ុន្តែផ្អែកតាមចម្លើយរបស់ជនរងគ្រោះបានឆ្លើយថាពុំធ្លាប់បានរួមភេទនោះទេមុនថ្ងៃកើតហេតុ តែបើពិនិត្យទៅលើកោលសវិច្ឆ័យឃើញថា សន្ទះព្រហ្មចារីរបស់ជនរងគ្រោះ មានការដាច់រហែក និងមានស្នាមជាំខ្លាំង ដែលជាសញ្ញាបញ្ជាក់ថា ធ្លាប់បានរួមភេទពីមុនមក។ ឃើញថាចម្លើយរបស់ជនរងគ្រោះ គ្រាន់តែឆ្លើយដោះសារដើម្បីឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ម្យ៉ាងវិញទៀតចម្លើយរបស់ជនរងគ្រោះពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីដោះបន្ទុកឱ្យជនជាប់ចោទ និងឱ្យតុលាការជឿជាក់បានឡើយ។

- តាមរបាយការណ៍សំយោគលេខៈ ១៩៩ ខ.ប.ស.បា.គ របស់អធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង បានបញ្ជាក់ថាៈ កាលពីថ្ងៃទីពុំចាំ ខែពុំចាំ ឆ្នាំ២០១៨ ឈ្មោះ [redacted] ម៉ុលនីកា ភេទស្រី អាយុ៩ឆ្នាំ (ជាជនរងគ្រោះត្រូវជាកូន) និងក្រុមគ្រួសារបានផ្លាស់មករស់នៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ពេលនោះឪពុកគេឈ្មោះ [redacted] សុខឡែន អាយុ៤២ឆ្នាំ បានលូកលេងប្រដាប់ភេទរូបគេ ប៉ុន្តែម្ដាយមិនដឹងទេ ។ លុះ១ខែក្រោយមករូបគេបានដេកក្នុងបន្ទប់ ជាមួយប្អូនប្រុស ហើយយប់ឡើងស្រាប់តែ ឪពុកគេចូលក្នុង បន្ទប់រួចបើកមុងចូលទៅរកគេ ហើយចាប់បឺតមាត់ចាប់ស្រាតខោ និងយកប្រដាប់ភេទគាត់ដាក់ចូលប្រដាប់ភេទរូបគេ ដោយសារឈឺពេក រូបគេបានគេចចេញ ប៉ុន្តែត្រូវឪពុកចាប់ដៃជាប់ ហើយផ្ដួលរូបគេទៅលើគ្រែ បន្ទាប់មកយកប្រដាប់ភេទគាត់ដាក់ចូលប្រដាប់ភេទរូបគេ រហូតចេញទឹកកាម ហើយបាននិយាយគំរាមថា កុំនិយាយប្រាប់ ម៉ាក់ប្រយ័ត្នគាត់អាកចោល។ កន្លះខែក្រោយមកទៀត ពេលយប់រូបគេដេកក្នុងបន្ទប់ជាមួយប្អូនប្រុស ឪពុកគេបានចូលទៅរកក្នុង បន្ទប់ហើយអោបថើប និងយកដៃលូកលេងប្រដាប់ភេទ រួចស្រាតខោ និងយកប្រដាប់ភេទ ដាក់ចូលប្រដាប់ភេទ រូបគេ រហូតចេញទឹកកាម។ បន្ទាប់មកទៀត ឪពុកគេតែងតែចាប់រំលោភ១សប្ដាហ៍ម្ដងកន្លះខែម្ដង។ លុះថ្ងៃទីខែពុំចាំឆ្នាំ២០២១ ឪពុកគេផឹកស្រាស្រវឹង ហើយសម្លឹងមើលតែរូបគេ ដោយមានការភ័យខ្លាច រូបគេទៅដេកផ្ទះអ៊ុំនៅភូមិកញ្ចរ ឃុំរលួស ស្រុកប្រាសាទបាគង ហើយម្ដាយបានទូរស័ព្ទសួរនាំនិងអោយទៅផ្ទះវិញ រូបគេបានប្រាប់ម្ដាយថា ខ្លាចប៉ាចាប់រំលោភ បន្ទាប់មកម្ដាយបានឱ្យរូបគេទៅផ្ទះវិញ ហើយអោយ ឪពុកស្បថ ឈប់រំលោភរូបគេ។ ក្រោយឪពុកស្បថហើយ មិនបានប្រព្រឹត្តលើរូបគេទៀតទេ ប៉ុន្តែមានអាកប្បកិរិយាមួម៉ៅ និងប្រចណ្ឌ ពេលគេទៅដើរលេងជាមួយមិត្តភក្តិប្រុស ឃើញដូចនោះរូបគេបានចេញពីផ្ទះទៅដេកនៅផ្ទះសង្សា តែពុំបានរួមភេទទេ ព្រឹកឡើងមកផ្ទះវិញ។ II.

- តាមចម្លើយរបស់ជនត្រូវចោទ, ដើមបណ្ដឹងរដ្ឋប្បវេណី, ជនរងគ្រោះ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នា អាចកំណត់បានថា ៖ ជនជាប់

Scanned with CamScanner

ចោទឈ្មោះ [redacted] សុខឡែន ពិតជាបានរំលោភសេពសន្ថវៈទៅលើកូនស្រីខ្លួនឈ្មោះ [redacted] ម៉ុលនីកា ពិតប្រាកដមែន ផ្អែកតាមចម្លើយរបស់ជនជាប់ចោទដែលបានសារភាពថាបានរំលោភសេពសន្ថវៈ មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះដែលបានបញ្ជាក់ថា មិនធ្លាប់បានរួមភេទមុនថ្ងៃកើតហេតុ ម្យ៉ាងវិញទៀតមានភាពស៊ីសង្វាក់គ្នានឹងលទ្ធផលកោលសវិច្ឆ័យ ដែលអាចបញ្ជាក់ថា កាលពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២១ ពិតជាមានករណី រំលោភសេពន្ថវៈ ពិតប្រាកដមែន។

- កាលពីឆ្នាំ ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ នៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ពិតជាមានករណី **រំលោភសេពសន្ថវមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ វ៉ា ពិតប្រាកដមែន។

- ជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ វ៉ា ពិតជាពិតជាបានធ្វើសកម្មភាពចាប់បញ្ចូលអង្គជាតុ ទៅលើជនរងគ្រោះជាកូនដែលជាអនីតិជន និងបានគម្រាមកំហែង ដែលច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ បទៈ **រំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ

- តំណាងអយ្យការបានសន្និដ្ឋានប្ដឹងសុំ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៣ អយធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្ដឹងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់ ឃើញថាការប្ដឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការ និងពិនិត្យពិចារណាចំពោះការប្ដឹងសុំនេះ។

- សេចក្ដីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ វ៉ា បានស្នើសុំ៖ ៖ **តុលាការនឹងពិនិត្យពិចារណា សម្រេចតាមច្បាប់។**

- ពុំមានភស្តុតាងណាមួយបញ្ជាក់ថាឈ្មោះ [redacted] សុខឡែន ហៅ វ៉ា មានបញ្ហាខាងស្មារតីនោះឡើយ ជនជាប់ចោទពិតជាបានយល់ដឹងអំពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ វ៉ា ពីបទ៖ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអាយុរបស់ជនរងគ្រោះ** ប្រព្រឹត្តនៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីឆ្នាំ ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡែន ហៅ វ៉ា ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សុខភាពរាងកាយ សេចក្ដីថ្លៃថ្នូរ សន្តិសុខ សណ្ដាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់រដ្ឋ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លក្ខិណា មិនបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់ចៅក្រមស៊ើបសួរឡើយ ម្យ៉ាងមិនបានទាមទារសំណង និងបានដកពាក្យបណ្ដឹងហើយ ដូច្នេះគប្បីតុលាការមិនពិចារណាចំពោះបញ្ហានេះឡើយ។

## ហេតុដូច្នេះសម្រេចសេចក្ដី

**១-ផ្ដន្ទាទោស ៖**

ឈ្មោះ [redacted] **សុខឡែន ហៅ វ៉ា** ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ ។**

Scanned with CamScanner

ពីបទ: **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសធាក់ទងទៅនឹងអាយុរបស់ជនរងគ្រោះ** ប្រព្រឹត្តនៅភូមិគោកត្រាច ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីឆ្នាំ ២០១៨ រហូតដល់អំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាម មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]